# អង្គការ សកម្មភាពសម្រាប់ការអប់រំនៅកម្ពុជា

**Kampuchea Action to Promote Education (KAPE)**

## សេចក្តីជូនដំណឹងស្តីពី

**ការអញ្ជើញចូលរួមដេញថ្លៃការផ្គត់ផ្គង់សៀវភៅរឿងសម្រាប់កុមារ របស់គម្រោង កុមារកម្ពុជារីករាយ នៃអង្គការ សកម្មភាពសម្រាប់ការអប់រំនៅកម្ពុជា ខេត្ត កំពង់ចាម ក្រោមជំនួយថវិកាពីអង្គការ កុមារកម្ពុជារីករាយ**

អង្គការ សកម្មភាពសម្រាប់ការអប់រំនៅកម្ពុជា (អង្គការ ខេប) សូមជម្រាបជូនដំណឹងដល់ក្រុមហ៊ុន និងអាជីវករ ឬអ្នកផ្គត់ផ្គង់សៀវភៅរឿងសម្រាប់កុមារ ក្នុងស្រុកទាំងអស់ ដែលបានចុះបញ្ជីត្រឹមត្រូវក្នុងព្រះរាជាណាចក្រកម្ពុជាឱ្យបានជ្រាបថា៖ គម្រោង កុមារកម្ពុជារីករាយ នៃអង្គការ សកម្មភាពសម្រាប់ការអប់រំនៅកម្ពុជា នឹងដាក់ឱ្យដេញថ្លៃជាសាធារណៈដើម្បីជ្រើសរើសក្រុមហ៊ុន និងអាជីវករ ឬអ្នកផ្គត់ផ្គង់ សម្រាប់ផ្គត់ផ្គង់សៀវភៅរឿងសម្រាប់កុមារ **ចំនួន៖ ៤,២៩៤ក្បាល (ដែលមាន ១១៣ ចំណងជើង)**។

ក្រុមហ៊ុន និងអាជីវករ ឬអ្នកផ្គត់ផ្គង់ ដែលមានចំណាប់អារម្មណ៍ សូមរៀបចំសម្រង់តម្លៃដាក់ដេញថ្លៃ មកអង្គការ សកម្មភាពសម្រាប់ការអប់រំនៅកម្ពុជា (អង្គការ ខេប) ដែលមានអាសយដ្ឋាននៅអាគារលេខ៖៤០៥, ភូមិទី៦, សង្កាត់ វាលវង់, ក្រុង កំពង់ចាម, ខេត្ត កំពង់ចាម **ចាប់ពីថ្ងៃទី៣០ ខែមីនា ឆ្នាំ ២០២៣ រហូតដល់ ថ្ងៃទី០៧ ខែមេសា ឆ្នាំ ២០២៣ វេលាម៉ោង ០៥:០០នាទីល្ងាចជាកំហិត**។

**ការបើកកញ្ចប់ឯកសារដេញថ្លៃនឹងប្រព្រឹត្តិទៅដោយផ្ទាល់ នាថ្ងៃទី១០ ខែមេសា ឆ្នាំ២០២៣ វេលាម៉ោង ០៩:៣០នាទី** ព្រឹកជាកំហិត នៅការិយាល័យកណ្តាលអង្គការ ខេប ខេត្ត កំពង់ចាម ។

<u>បញ្ជាក់</u>៖

- អ្នកដេញថ្លៃទាំងអស់ត្រូវបំពេញនៅក្នុងតារាងប៉ាន់ស្មានតម្លៃនូវ៖ តម្លៃសៀវភៅមួយក្បាល គិតជាប្រាក់រៀល និងតម្លៃសរុប គិតជាប្រាក់រៀល (មានបញ្ជីឈ្មោះសៀវភៅរឿងជូនភ្ជាប់)។
- អ្នកដេញថ្លៃទាំងអស់ត្រូវបំពេញបែបបទដាក់ពាក្យដេញថ្លៃតាមទម្រង់ដូចបានជូនភ្ជាប់ បន្ទាប់មកដាក់ចូលស្រោមសំបុត្របិទជិត ដោយមានចុះហត្ថលេខា ឬបោះត្រា នៅលើស្រោមសំបុត្រ រួចបញ្ជូនមកការិយាល័យរបស់ អង្គការ ខេប (ស្ថិតនៅក្នុង បរិវេណ សាលាគរុកោសល្យ និង វិក្រឹតការ ខេត្ត កំពង់ចាម) អាគារលេខ៖ ៤០៥, ភូមិទី៦, សង្កាត់ វាលវង់, **ស្រុក កំពង់ចាម, ខេត្ត កំពង់ចាម ឱ្យបានមុនថ្ងៃកំណត់**។
- អ្នកដេញថ្លៃទាំងអស់ត្រូវចូលរួមបើកកញ្ចក់ដេញថ្លៃឱ្យទាន់ពេលវេលាតាមកាលបរិច្ឆេទ នៅថ្ងៃទី១០ ខែមេសា ឆ្នាំ២០២៣។ ប្រសិនបើចូលរួមមិនទាន់ពេលវេលា ឬក៏អវត្តមាន ឯកសារដេញថ្លៃរបស់ក្រុមហ៊ុន និងអាជីវករ ឬអ្នកផ្គត់ផ្គង់នោះ ត្រូវបានចាត់ទុកជាអាសាបង់។
- យើងខ្ញុំសូមរក្សាសិទ្ធិផ្លាស់ប្តូរកាលបរិច្ឆេទបើកសម្រង់តម្លៃបើមានការចាំបាច់ ហើយយើងខ្ញុំនឹងជូនដំណឹងជាមុនទៅក្រុមហ៊ុនដែលបានផ្ញើឯកសារដេញថ្លៃមក។

**ព័ត៌មានផ្សេងៗសូមទំនាក់ទំនង៖**

អង្គការ សកម្មភាពសម្រាប់ការអប់រំនៅកម្ពុជា (អង្គការ ខេប)

អាសយដ្ឋាន ៖ សាលាគរុកោសល្យ និង វិក្រឹតការ ខេត្ត កំពង់ចាម អាគារលេខ៖៤០៥, ភូមិទី៦, សង្កាត់ វាលវង់, ក្រុង កំពង់ចាម, ខេត្ត កំពង់ចាម។


ឈ្មោះ ៖ លោក ឈួន សាវ៉ាន ប្រធានរដ្ឋបាល និងធនធានមនុស្ស

ទូរសព្ទ ៖ ០១២ ៧៥២ ៥៥៣ ឬ ០៩៦ ៤៦៤ ៧៧៧៧

ឈ្មោះ ៖ លោក សោម វាសនា មន្ត្រីលទ្ធកម្ម និងរដ្ឋបាល

ទូរសព្ទ ៖ ០១១ ៣៧៤ ៧៥៤ ឬ ០១៥ ៥១២ ៣៤២


ថ្ងៃព្រហស្បតិ៍ ៩កើត ខែចេត្រ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

កំពង់ចាម, ថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២៣

**នាយកប្រតិបត្តិ**

KAMPUCHEA ACTIONS TO PROMOTE EDUCATION ORG

**សៅ វណ្ណា**